# សុន្ទរកថា

## ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## ថ្លែងក្នុងឱកាសប្រារព្ធពិធីមិទ្ទីញអបអរសាទរ
## ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ០៥ មិថុនា
## រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣

**ជាបឋម**-

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាអរិយវង្ស **សៅរ៍ ចន្ទថុល្ល** ព្រះអនុគណខណ្ឌចំការមន និងជាព្រះចៅអធិការវត្តលង្កា និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!
- សូមគោរពឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញជាទីរាប់អាន !
- សូមគោរពលោកជំទាវ **ទន់ សារ៉ុម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡាជាទីរាប់អាន !
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី មន្ត្រីរាជការ អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូ បងប្អូនប្រជាពលរដ្ឋទាំងអស់ ទាំងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីមេត្រី !
- ក្មួយៗសិស្សានុសិស្សទាំងអស់ជាទីស្រឡាញ់រាប់អាន !

ថ្ងៃនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាន ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយប្រកបដោយក្តីមោទនជាតិខ្ពស់ និងសូមស្វាគមន៍ដល់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី ជាមន្ត្រីរាជការ ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សទាំងអស់ ដែលបានអញ្ជើញមកចូលរួមជាមួយប្រតិភូក្រសួងបរិស្ថានយើងខ្ញុំ ក្នុងការរៀបចំមិទ្ទីញប្រារព្ធពិធីអបអរសាទរទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ។

ទិវាបរិស្ថាន០៥ មិថុនា ឆ្នាំ២០១៣ នេះ គឺជាឆ្នាំទី៣០ នៃព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់ចលនាអន្តរជាតិ ដែលត្រូវបានរៀបចំឡើងជាសកល ក្នុងគោលបំណងជំរុញឲ្យប្រទេសនានាលើសកលលោកយកចិត្តទុកដាក់ដោះស្រាយនូវបញ្ហាបរិស្ថានរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង ដើម្បីបុព្វហេតុបរិស្ថានភពផែនដី តុល្យភាពអេកូឡូស៊ី និងការអភិវឌ្ឍន៍ដោយចីរភាព សំរាប់ជាផលប្រយោជន៍រួមដល់មនុស្សជាតិគ្រប់ជាតិសាសន៍ និងការរីកចំរើនក្នុងពិភពលោកទាំងមូល។ ព្រះរាជាណាចក្រកម្ពុជា ក៏បានទទួលស្គាល់ និងប្រារព្ធទិវាបរិស្ថានពិភពលោកជារៀងរាល់ឆ្នាំផងដែរ។

បន្ថែមពីលើនេះទៀតរាជរដ្ឋាភិបាលកម្ពុជា ក៏បានកំណត់យកថ្ងៃទី០៥ មិថុនា ជារៀងរាល់ឆ្នាំថាជា "ទិវាបរិស្ថានជាតិ" និងជាថ្ងៃប្រារព្ធព្រមគ្នានូវ"ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក" ដោយយោងតាមអនុក្រឹត្យលេខ១៥អនក្រ-បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦។ ការប្រារព្ធទិវាបរិស្ថាន ០៥ មិថុនា ជារៀងរាល់ឆ្នាំ គឺធ្វើឡើងក្នុងគោលបំណងដាស់សតិអារម្មណ៍មនុស្សគ្រប់ៗរូប ឲ្យមានការយកចិត្តទុកដាក់គិតគូរ

ពីហានិភ័យបរិស្ថាននានា ដែលតែងតែកើតមានមកលើភពផែនដី និងជួយពញ្ញាក់ស្មារតីដល់សហគមន៍ជាតិយើងទាំងអស់គ្នា ឲ្យយកចិត្តទុកដាក់ពីបញ្ហាបរិស្ថាន ដើម្បី ជាផលប្រយោជន៍ដល់មនុស្សជាតិគ្រប់ៗរូប គ្រួសារនីមួយៗ និងសេដ្ឋកិច្ចសង្គមជាតិយើងទាំងមូល។

នាឱកាសនេះ ការចូលរួមរបស់ព្រះតេជគុណព្រះថេរានុថេរៈ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្ស គឺជាសក្ខីភាពមួយដ៏អស្ចារ្យ ដែលបង្ហាញពីការយកចិត្តទុកដាក់របស់ប្រជាជាតិយើងទាំងអស់គ្នា ជាមួយប្រជាជាតិលើសកលលោក ដើម្បីបុព្វហេតុរួមចំណែកការពារ និងថែរក្សាគុណភាពបរិស្ថានភពផែនដី ឲ្យឈានឆ្ពោះទៅរកនិរន្តរភាព និងភាពស្រស់បំព្រងជានិច្ចសំរាប់មនុស្សជាតិបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយៗទៀត។

**គណៈអធិបតី និងអង្គមិត្តីញទាំងមូលជាទីគោរព** !

ដូចឆ្នាំមុនៗដែរ អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិហៅកាត់ថា (UNEP) បានលើកឡើងនូវប្រធានបទថ្មីសម្រាប់ឆ្នាំ២០១៣ ដែលមានខ្លឹមសារថា "ត្រូវពិចារណា-ពេលបរិភោគ-ដើម្បីសន្សំសំចៃធនធាន" (THINK-EAT-SAVE)។ ប្រធានបទនេះបានបង្កប់នូវអត្ថន័យយ៉ាងជ្រាលជ្រៅបំផុត ដែល ចង់បញ្ជាក់ថា៖ ពាក្យ "ត្រូវពិចារណា-ពេលបរិភោព-ដើម្បីសំន្សំសំចៃធនធាន" គឺជាយុទ្ធសាស្ត្រប្រឆាំងទៅនិងសំណល់ចំណីអាហារ និងការបាត់បង់ចំណីអាហារ ដើម្បីជួយលើកទឹកចិត្តយើងឲ្យចូលរួមក្នុងការជម្រុះចោលនូវទម្លាប់ខ្ជះខ្ជាយចំណីអាហាររបស់យើង។ អង្គការកសិកម្ម និងស្បៀងអាហារសហប្រជាជាតិ (FAO) បានអះអាងថាជារៀងរាល់ឆ្នាំមានស្បៀងអាហារប្រមាណ ១,៣ពាន់លានតោន ត្រូវបានខ្ជះខ្ជាយចោលជាសំណល់ចំណីអាហារនៅទូទាំងពិភពលោក។ លើសពីនេះទៀតដោយសារអតុល្យភាពសមធម៌ដ៏មហិមានៅក្នុងជីវភាពរស់នៅ និងឥទ្ធិពលវិនាសកម្មយ៉ាងធ្ងន់ធ្ងរទៅលើបរិស្ថាន បានជំរុញឲ្យមានការលើកឡើងនូវប្រធានបទសំរាប់ឆ្នាំនេះគឺ៖ "**ត្រូវពិចារណា-ពេលបរិភោគ-ដើម្បីសន្សំសំចៃធនធាន**" (THINK-EAT-SAVE) ដែលជាពាក្យស្លោកក្រើនរំលឹកយើងទាំងអស់គ្នា ឲ្យកាន់តែយកចិត្តទុកដាក់បន្ថែមទៀតពីផលប៉ះពាល់លើបរិស្ថាន ដោយសារជំរើសចំណីអាហាររបស់យើង និងជំរុញឲ្យយើងធ្វើការសំរេចចិត្តប្រកបដោយវិចារណញ្ញាណដ៏ប្រសើរមុនពេលបរិភោគ។ ម៉្យាងវិញទៀត សំណល់ចំណីអាហារគឺជាការខាតបង់ដ៏ធំសំបើមទៅលើធនធានធម្មជាតិ និងរួមចំណែកបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន ប្រសិនបើចំណីអាហារ ទាំងនោះ ត្រូវបានគេខ្ជះខ្ជាយ គឺមានន័យថារាល់ធនធាននិងធាតុចូលទាំងអស់ ដែលបានប្រើក្នុងគ្រប់ខ្សែសង្វាក់ផលិតកម្មចំណីអាហារនិងត្រូវបានបាត់បង់ផងដែរ។ ដូចនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឆ្លាតវៃ របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខបាននិងកំពុងដាក់ចេញនូវគោលនយោបាយនិងបទបញ្ញាជាច្រើនក្នុងថែរក្សា និងគាំពារគុណភាពបរិស្ថាន តុល្យភាពអេកូឡូស៊ី និងធនធានជីវៈចំរុះ ។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍបៃតង ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រមួយឆ្នាំឲ្យបាន ១% ។ ជាសំខាន់អភិវឌ្ឍន៍បៃតងនៅកម្ពុជាផ្តោតលើតុល្យភាពនៃការអភិវឌ្ឍ និងវឌ្ឍនភាពរវាង វិស័យសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដែលជាយុទ្ធវិធីឈ្នះ-ឈ្នះ ដើម្បីកំណើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពបរិស្ថាន និងអារ្យធម៌បៃតងរុងរឿង។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០ បានបង្ហាញនូវចក្ខុវិស័យវែងឆ្ងាយ និងយ៉ាងច្បាស់លាស់ដើម្បីជំរុញ និងលើកកំពស់ការអភិវឌ្ឍបៃតងមួយក្នុងការសន្សំសំចៃធនធាន ការប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ គិតទាំងការកែលំអឲ្យប្រសើរទំនាក់ទំនងផលិតកម្ម និងការប្រើប្រាស់ ពិសេសការផ្លាស់ប្តូរទម្លាប់ នៃការប្រើប្រាស់ និងផលិតប្រកបដោយនិរន្តរភាព (Sustainable Production and Consumption Pattern Change ) ។

**គណៈអធិបតី និងអង្គមិទ្ទីញទាំងមូលជាទីគោរព** !

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណ និងកោតសរសើរផងដែរ ចំពោះស្នាដៃរបស់អាជ្ញាធររាជធានីភ្នំពេញ មន្ត្រីមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងសហគមន៍មូលដ្ឋានដែលកន្លងមកបានពុះពាររាល់ឧបសគ្គ និងបានរួមគ្នាស្តារឡើងវិញនូវបរិស្ថានសង្គមជាតិឲ្យបានប្រសើរស្រស់បំព្រង។ ទាំងនេះគឺជាសមិទ្ធផលមួយគួរឲ្យកត់សំគាល់ ចាប់តាំងពីប្រទេសជាតិយើងទទួលបានសុខសន្តិភាព និងកំពុងបោះជំហានយ៉ាងស្វាហាប់ជាមួយនិងសុខសន្តិភាព ការបង្រួបបង្រួមជាតិ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធមនុស្ស។

ទន្ទឹមនេះដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូរអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ផ្នែកបរិស្ថានទាំងអស់ ដែលបានសហការ និងសហប្រតិបត្តិការលើការងារគ្រប់គ្រងបរិស្ថានកន្លងមក និងជាពិសេសសូមថ្លែងអំណរគុណចំពោះ៖

- កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ( CCCA )
- ក្រុមហ៊ុនខ្មែរ ប្រ៊ូវើរី លីមីធីត ( ស្រាបៀរកម្ពុជា )
- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា NGO Forum on Cambodia
- អង្គការសង្គ្រោះសត្វព្រៃ Save Cambodia's Wildlife
- Wildlife Alliance
- ក្រុមហ៊ុនស៊ិនទ្រីកម្ពុជា (ចំកាត់)
- ក្រុមហ៊ុនផ្សារឡាក់គីប្រ្លួប
- អង្គការម្លប់បៃតង

ដែលបានជួយឧបត្ថម្ភទាំងស្មារតី ថវិកា និងសំភារៈដើម្បីធ្វើឲ្យ ការប្រារព្ធទិវាបរិស្ថានជាតិនិង បរិស្ថានពិភពលោកនៅពេលនេះ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងប្រកបដោយផ្លែផ្កា។

ខ្ញុំមានសង្ឃឹម និងមានជំនឿ ជឿជាក់ថា ស្មារតីនៃការប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ០៥ មិថុនា ឆ្នាំ ២០១៣ នាពេលនេះ នឹងធ្វើឲ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ មានការយល់ដឹង ហើយយកការយល់ដឹងក្នុងឱកាសនេះប្រែក្លាយជាការអនុវត្តជាក់ស្តែង និងអនុវត្តជាប្រចាំដើម្បីបុព្វហេតុបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបរិស្ថានពិភពលោកឲ្យមាននិរន្តរភាព។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរព្រះតេជគុណគ្រប់ព្រះអង្គ និងប្រសិទ្ធពរជ័យជូនចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងក្មួយៗ សិស្សានុសិស្ស សូមបានប្រកបតែសិរីសួស្តីជ័យមង្គលវិបុលសុខ មានប្រាជ្ញាឈ្លាសវៃ ដើម្បីចូលរួមកសាងមាតុភូមិអង្គរដ៏បវរនៃយើងឲ្យកាន់តែអភិវឌ្ឍ និងរីកចំរើនលើគ្រប់វិស័យកុំបីឃ្លៀងឃ្លាតឡើយ ។

**ជយោ! ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ឆ្នាំ២០១៣**

**សូមអរព្រះគុណ និងអរគុណ!**